Disability Rights California

*គ្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ា*
*ទូរសព្ទហៅឥតគិតថ្លៃ (800) 776-5746*

# តើអ្វីទៅជាកម្មវិធី Adult Expansion / MAGI Medi-Cal ?

***ខែឧសភា ឆ្នាំ 2016 ការបោះពុម្ពផ្សាយ 5551.06***

Affordable Care Act [ACA] (ច្បាប់សេវាថែទាំ មានថ្លៃសមរម្យ) (ហៅថា Obamacare ផងដែរ) បានបង្កើនចំនួនអ្នកដែលអាច ទទួលបាន Medicaid (Medi-Cal នៅកាលីហ្វ័រញ៉ា)។ «Adult Expansion Medi-Cal (កម្មវិធី Medi-Cal ពង្រីកវិសាលភាព សម្រាប់មនុស្សពេញវ័យ)» ឬ Medi-Cal សម្រាប់ «មនុស្សពេញវ័យ ដែលគ្មានកូន» គឺជាផ្នែកនៃកម្មវិធី ដែលហៅថា «MAGI» Medi-Cal ក្រោម ACA ។ «MAGI» Medi-Cal សំដៅលើ កម្មវិធី Medi-Cal ដែលប្រើ MAGI (ចំណូលដុល ដែលមានការកែសម្រួល) ដើម្បីកំណត់សិទ្ធិទទួលបានសេវា ពី Medi-Cal ផ្អែកលើកត្តាហិរញ្ញវត្ថុ ។

## តើអ្នកណាខ្លះ ដែលមានសិទ្ធិទទួលបានផលពី Adult Expansion Medi-Cal ?

លោកអ្នកអាចទទួលបានផលពី Medi-Cal ក្រោមកម្មវិធីថ្មី Adult Expansion Medi-Cal ប្រសិនបើ ៖

- លោកអ្នកមានអាយុចន្លោះ 19 ឆ្នាំ និង 64 ឆ្នាំ ។
- ចំណូល MAGI របស់លោកអ្នក ស្ថិតក្រោម 138% នៃកម្រិតភាពក្រីក្រសហព័ន្ធ (FPL) ។[i]
- អ្នកគ្មានគត៌នោះទេ ។
- លោកអ្នកមិនទទួលបានផលពី Medicare នោះទេ ។
- លោកអ្នកមិនទទួលបានផលពី Medi-Cal ដោយគ្មានការជួយចេញថ្លៃ នោះទេ ។

## តើខ្ញុំដឹងបានថា ចំណូល MAGI របស់ខ្ញុំ ស្ថិតក្រោម 138%[ii] ដោយរបៀបណាដែរ ?

លោកអ្នកមិនចាំបាច់ត្រូវគិតគូរ ដោយខ្លួនឯងនោះទេ ។ លោកអ្នកអាចដាក់ « ពាក្យស្នើទូទៅមួយ» សម្រាប់ MAGI Medi-Cal តាមរយៈ Covered California (កម្មវិធីរដ្ឋកាលីហ្វ័ញ៉ា ដែលមានធានារ៉ាប់រង) ការិយាល័យ Medi-Cal តំបន់ ឬទី

កន្លែងមួយចំនួន ផ្សេងៗ ទៀត ។ លោកអ្នកអាចដាក់ពាក្យស្នើសុំទូទៅមួយ តាមអុីនធឺណែត នៅគេហទំព័ររបស់ Covered California ។ ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ តាមគេហទំព័ររបស់ Medi-Cal តំបន់ នោះវានឹងបញ្ជូនលោកអ្នក ភ្ជាប់ទៅ គេហទំព័ររបស់ Covered California ដើម្បីឱ្យលោកអ្នកអាចដាក់ពាក្យស្នើសុំ MAGI Medi-Cal បាន ។

## តើមានវិធានអ្វីខ្លះ ដែលបញ្ជាក់ អំពីចំនួនទឹកប្រាក់ ឬទ្រព្យសម្បត្តិ ដែលខ្ញុំអាចមាន ហើយនៅតែអាចទទួលបានផលពី Adult Expansion Medi-Cal ដែរឬទេ ?

បាទ/ចាស មាន ។ ប៉ុន្តែ វិធានទាំងនោះ ខុសពី pre-ACA Medi-Cal (កម្មវិធីមុន ACA Medi-Cal)។ Pre-ACA Medi-Cal មានដែនកម្រិត តឹងរឹង អំពីកម្រិតចំណូល និងបរិមាណទ្រព្យសម្បត្តិ ដែលលោកអ្នកអាចមាន ។ MAGI Medi-Cal ប្រើមធ្យោបាយផ្សេង ក្នុងការគណនាចំណូល ហើយអនុញ្ញាតឱ្យបុគ្គលនៅលីវ អាចមានចំណូល MAGI រហូតដល់ $16,242 ក្នុងមួយឆ្នាំ ។ កម្រិតចំណូលនេះ គឺ 138% នៃកម្រិតភាពក្រីក្រសហព័ន្ធ ។ ទោះជាយ៉ាងនេះក្តី ក្រោម MAGI Medi-Cal គ្មាន ការមិនរាប់បញ្ចូលចំណូល ឬការកាត់ចំណូល ផ្សេងពីការកាត់ចេញមួយចំនួន ដែលបានប្រើ ដើម្បីកំណត់កម្រិតចំណូល MAGI របស់លោកអ្នកនោះទេ ។ និងដោយខុសពី pre-ACA Medi-Cal ***មិនមាន*** ទុនសម្រាប់ MAGI Medi-Cal[iii] ទេ។ នេះមានន័យថា អ្នកអាចមានទទួលបានលើសពី $2,000 ក្នុងមួយនាក់/3,000 ក្នុងកម្រិតប្រភពចំណូលពីរនាក់ប្តីប្រពន្ធនៃកម្មវិធី pre-ACA Medi-Cal[iv]។

## ចុះបើខ្ញុំមានកម្មវិធី Medi-Cal ដែលចែករំលែកថ្លៃចំណាយ នាពេលបច្ចុប្បន្ននេះ ? តើខ្ញុំអាចដូរមកកម្មវិធី Adult Expansion Medi-Cal បានដែរឬទេ ?

បាទ/ចាស (មាន!)។ លោកអ្នកអាចទំនាក់ទំនងទៅ ការិយាល័យ Medi-Cal តំបន់ នៅមូលដ្ឋានរបស់លោកអ្នក ហើយស្នើសុំពួកគេ ឱ្យពិនិត្យមើល ថាតើលោកអ្នកមានសិទ្ធិអាចទទួលបានផលពី MAGI Medi-Cal ដោយមិនចាំបាច់ជួយចេញថ្លៃបានដែរ ឬយ៉ាងណានោះ ។ County (តំបន់) ក៏នឹងពិនិត្យមើលថាតើ លោកអ្នកមានសិទ្ធិ ទទួលបានផលពី MAGI Medi-Cal នៅក្នុងការកំណត់ឡើងវិញ លើ កម្រិតចំណូលប្រចាំឆ្នាំ របស់លោកអ្នកដែរ ឬយ៉ាងណានោះ ។ County (តំបន់) នឹងផ្តល់ជូន MAGI Medi-Cal ដល់លោកអ្នក ប្រសិនបើលោកអ្នកមានសិទ្ធិទទួលបាន ។

## តើមានសេវាអ្វីខ្លះ ដែលខ្ញុំអាចទទួលបានពី Adult Expansion Medi-Cal?

អ្នកអាចទទួលសេវាគ្រប់ប្រភេទដែលមានក្រោម Medi-Cal ដែលមានលក្ខណៈទៀងទាត់ដែលមានជាអាទិ៍ កន្លែងថែទាំវេជ្ជសាស្ត្រ, សេវាជំនួយរស់នៅក្នុងផ្ទះ

(IHSS), និងសេវាថែទាំវេជ្ជសាស្ត្ររយៈពេលវែងផ្សេងៗទៀត ***ដោយមិនចាំបាច់មានទុនសកម្ម*** ***ការធ្វើតេស្តទ្រព្យសម្បត្តិ ។*** លើសពីនេះទៅទៀត លោកអ្នកអាចទទួលបាន សេវាប្រើសារធាតុញៀន និងសេវាថែទាំសុខភាពផ្លូវចិត្ត ពីផែនការគ្រប់គ្រងដោយ Medi-Cal និងពីសេវាសុខភាពផ្លូវចិត្តតំបន់/សេវាសុខភាព រូបកាយតំបន់ ផងដែរ ។ [vi] ប្រសិនបើលោកអ្នកចង់បាន សេវាដល់ផ្ទះ និង community-based waiver services [HCBS] (សេវាលះបង់តាមសហគមន៍) នោះ លោកអ្នកអាចដាក់ពាក្យស្នើសុំ pre-ACA Medi-Cal តាមរយៈការិយាល័យ Medi-Cal តំបន់ ។ អ្នកធ្វើដូច្នេះបានតាមរយៈការបំពេញ ទម្រង់បែបបទ[vii] SAWS 2 Plus។

## តើមានប្រភពព័ត៌មានអ្វីខ្លះ ប្រសិនបើខ្ញុំមានចម្ងល់ច្រើនជាងនេះទៅទៀត ?

នៅផ្នែកខាងក្រោម នៃឯកសារនេះ យើងខ្ញុំមានរាយប្រភពព័ត៌មាន តាមអុីនធឺណែត ដែលអាចមាន ប្រយោជន៍ ដោយអាចឱ្យលោកអ្នក ធ្វើការស្រាវជ្រាវបន្ថែមទៀតបាន ។ លើសពីនេះទៅទៀត ទីភ្នាក់ងារ Medi-Cal តំបន់របស់លោកអ្នក ដែលមានគេហទំព័រ http://www.dhcs.ca.gov/services/medi-cal/Pages/CountyOffices.aspx និង Covered California ដែលមានគេហទំព័រ www.coveredca.com និង លេខទូរសព្ទ 1-800-300-1506 អាចឆ្លើយតបនឹងចម្ងល់របស់លោកអ្នកបាន ។

អង្គភាពខាងក្រោមនេះ អាចផ្តល់ជំនួយ ផ្នែកតស៊ូមតិ ៖

- Disability Rights California (សិទ្ធិជនពិការរដ្ឋកាលីហ្វ័រញ៉ា), ដែលមានគេហទំព័រ www.disabilityrightsca.org, និង លេខទូរសព្ទ 1-800-776-5746 ឬ
- អង្គភាពសេវាផ្នែកច្បាប់ នៅមូលដ្ឋានរបស់លោកអ្នក Health Consumer Alliance (សម្ព័ន្ធអ្នកប្រើប្រាស់សេវាសុខាភិបាល) បានរាយឈ្មោះអង្គភាពទាំងនេះ នៅគេហទំព័រ http://healthconsumer.org/index.php?id=partners

យើងខ្ញុំចង់ស្តាប់ឮពីអ្នក! សូមបំពេញសម្រង់មតិខាងក្រោម អំពីការផ្សព្វផ្សាយរបស់យើងខ្ញុំ ហើយប្រាប់ឱ្យយើងខ្ញុំដឹង អំពីស្ថានភាពរបស់លោកអ្នក ! https://docs.google.com/forms/d/1d6ezTl2M5UMAWU66exLbc1SQ9wDPzvtuS3AGR4-cgwE/viewform?c=0&w=1

*គម្រោងការណ៍ការពារ & គាំទ្រនៃរដ្ឋកាលីហ្វ័រញ៉ាទទួលបានការឧបត្ថម្ភថវិកាពីប្រភពជាច្រើន សម្រាប់បញ្ជីអ្នកឧបត្ថម្ភថវិកាពេញលេញ ឆ្ពោះទៅកាន់ទំព័រ*

*ដែលមានតំណ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html។

---

[i] មជ្ឈមណ្ឌលជាតិអនុវត្តន៍ច្បាប់ការពារមនុស្សចាស់ បានសរសេររបាយការណ៍សង្ខេបសំខាន់អំពីការពង្រីកកម្មវិធី Medicaid នៅរដ្ឋកាលីហ្វ័រញ៉ាដែលលើកយកមកដោះស្រាយនូវបញ្ហាសិទ្ធិទទួលបានប្រាក់ចំណូល។ សូមចូលមើល http://nsclcarchives.org/wp-content/uploads/2013/11/1CA-Eligibility-Brief-4.pdf ៖ «រូបមន្ត MAGI មិនរាប់បញ្ចូល ចំណូលមួយចំនួន ដូចជា អត្ថប្រយោជន៍អតីតយុទ្ធជន ជំនួយគាំទ្រកូនដែលទទួលបាន ព្រមទាំង អាហារូបករណ៍ ជំនួយមូលនិធិឥតសំណង និងរង្វាន់ ដែលបានប្រើ សម្រាប់គោលដៅអប់រំនោះទេ ។ Expansion Medi-Cal ក៏នឹងអនុញ្ញាតឱ្យមាន ការកាត់ចេញ នូវចំណូលផ្សេងទៀតដែលមិនទទួលបានការអនុញ្ញាត ក្រោមការគណនាចំណូលរបស់ Medi-Cal ដែលមានអនុវត្ត ពីមុនមក រួមមាន ប្រាក់របប (alimony) ដែលបានទទួល និងវិភាគទានមុនបង់ពន្ធ សម្រាប់ចំណាយនានា ដូចជា លើសេវាថែទាំកូន ឬការចូលនិវត្តន៍ (ទោះបីជា ផ្ទុយទៅវិញ មិនមានការអនុញ្ញាត ឱ្យមានការកាត់ចេញ A&D FPL ធម្មតា សម្រាប់ប្រាក់បុព្វលាភធានារ៉ាប់រងសុខភាព ក៏ដោយ»។ U.C. Berkeley Labor Center (មជ្ឈមណ្ឌលការងារ ប៊ើលី) មានផ្ដល់ជូន ទំព័រព័ត៌មាន មួយទំព័រដែលសេចក្ដីពន្យល់សាមញ្ញ អំពីរបៀប គណនា MAGI ។ ទំព័រនោះ អាចរកបាននៅទីនេះ ៖ http://laborcenter.berkeley.edu/healthcare/MAGI_summary13.pdf «ត្រឡប់មក ឯកសារចំបង»

[ii] សម្រាប់ព័ត៌មានបន្ថែម អំពី MAGI សូមមើល «មគ្គុទេសក៍របស់អ្នកតស៊ូមតិចំពោះ MAGI» របស់ National Health Law Program (កម្មវិធីច្បាប់សុខាភិបាលជាតិ) ដែលអាចរកបាននៅ http://www.healthlaw.org/publications/agmagi «ត្រឡប់មក ឯកសារចំបង»

[iii] Pre-ACA Medi-Cal សាកសួរព័ត៌មាន អំពីទ្រព្យសម្បត្តិ របស់លោកអ្នក ហើយប្រសិនបើលោកអ្នក មានទ្រព្យសម្បត្តិច្រើន នោះលោកអ្នកនឹងគ្មានសិទ្ធិទទួលបានផលពី Medi-Cal នោះទេ ។ «ត្រឡប់មក ឯកសារចំបង»

[iv] http://nsclcarchives.org/wp-content/uploads/2013/11/1CA-Eligibility-Brief-4.pdf «ត្រឡប់មក ឯកសារចំបង»

[v] រដ្ឋកាលីហ្វ័រញ៉ា បានជូនដំណឹងដល់តំបន់រួចហើយថា MAGI expansion adults ដែលត្រូវការសេវាសម្បទាផ្ដល់ការមើលថែទាំ អាចទទួលបានសេវានេះ ក្រោមសិទ្ធិទទួលបាន MAGI ដោយគ្មាន ការធ្វើតេស្តទ្រព្យសម្បត្តិ ៖ http://www.dhcs.ca.gov/services/medi-cal/eligibility/Documents/MEDIL2014/MEDILI14-06.pdf ។ រដ្ឋកាលីហ្វ័រញ៉ា ក៏បានជូនដំណឹងដល់តំបន់រួចហើយថា MAGI expansion adults មានផ្ដល់ជូន

---

សម្រាប់សេវា LTSS សហគមន៍ ផងដែរ ៖ http://www.dhcs.ca.gov/services/medi-cal/eligibility/Documents/MEDIL2014/MEDILI14-11.pdf ។ ទោះបីជា គ្មានការកំណត់រកពិការភាព សម្រាប់ MAGI Medi-Cal ក៏ដោយ ក៏លោកអ្នកត្រូវបំពេញឱ្យបានតាម បទដ្ឋានវេជ្ជសាស្ត្រចាំបាច់ សម្រាប់សេវា LTSS ។ «ត្រឡប់មក ឯកសារចំបង»

vi សូមមើល http://www.dhcs.ca.gov/formsandpubs/laws/Documents/Pending%20SPA%2013-038%20not%20ADA.pdf; http://www.dhcs.ca.gov/formsandpubs/Documents/MMCDAPLsandPolicyLetters/APL2013/APL13-021.pdf ។ «ត្រឡប់មក ឯកសារចំបង»

vii http://www.cdss.ca.gov/cdssweb/entres/forms/English/SAWS2PLUS.pdf «ត្រឡប់មក ឯកសារចំបង»